បើសិនជារូបអ្នក ឬអ្នកជាទីស្រឡាញ់ ត្រូវបានសំភាសន៍នៅក្នុងពន្ធនាគារ ដោយ ICE (អាយស៊ីអ៊ី) នេះ ដោយគ្មានការយល់ព្រមពីរូបអ្នក ឬត្រូវបានផ្ទេរទៅ ជំ (អាយស៊ីអ៊ី) ដោយខុស ចេញពីកន្លែងពន្ធនាគារតាមតំបន់នោះ - សូមមេត្តា-ទូរស័ព្ទមកលេខ **1-844-878-7801** ។ យើងឆែកមើលសារបណ្តាំរៀងរាល់ថ្ងៃ។

ទង្វើការពិត TRUTH Act (ទ្រូអាក់) នេះ គឺជាជំហានមួយបន្ថែមទៀត ក្នុងការប្រឆាំង ដើម្បីយក ICE (អាយស៊ីអ៊ី) ចេញពីកាលីហ្វញ៉ា។ សិក្សាបន្ថែមទៀតនៅក្នុងបណ្តាញ **www.catruthact.org**

**មិនមានបំណង ផ្តល់ដំបូន្មានផ្នែកច្បាប់ៗ**

# The TRUTH ACT: យល់ដឹងពីសិទ្ធិរបស់អ្នក!

**ចាប់ផ្តើមពី ខែមករា ទី១ ឆ្នាំ២០១៧ គឺមានច្បាប់ថ្មី ហៅថា ទង្វើការពិត ទ្រូធៈ រ៉ាក (ទ្រូអាក់) ដែលការពារ មូលដ្ឋានសិទ្ធិ ជនអន្តោប្រវេសន៍ ដែលជាប់នៅក្នុងពន្ធនាគារតាមតំបន់ៗ**

## អ្នកតែងតែមានសិទ្ធិ  នៅស្ងៀមស្ងាត់ជានិច្ច។

នៅពេលនិយាយជាមួយ ឬនៅពីមុខ ភ្នាក់ងារច្បាប់ព្រហ្មទ័ណ្ឌនោះ អ្វីៗដែលអ្នកបាននិយាយ គឺអាច និងយកមកប្រើ ប្រាស់ប្រឆាំងជាមួយរូបអ្នកវិញ - សូមកុំនិយាយអំពីសភាពអន្តោប្រវេសន៍របស់អ្នក  សញ្ជាត្តិពលរដ្ឋ  នៅពេលណា ឬ របៀបអ្នកចូលមក ស្រុកអាមេរិកនេះ  ឬអ្នកមកពីទីណា។

## អ្នកមានសិទ្ធិក្នុងការនិយាយថា " ទេ " ចំពោះបទសំភាសន៍ ជាមួយអន្តោប្រវេសន៍ និងភ្នាក់ងារគយ ឡីជមែ

នៅក្រោមច្បាប់ ទង្វើការពិត  TRUTH Act (ទ្រូអាក់) និង ICE (អាយស៊ុអុិ) អាចធ្វើបទសំភាសន៍រូបអ្នក នៅក្នុង ពន្ធនាគារ ប្រសិនជាអ្នក *ចុះហត្ថលេខា* លើទម្រង់យល់ព្រមជាមុនសិន និងយល់ព្រមធ្វើបទសំភាសន៍។ នេះ មានន័យថា អ្នកមានសិទ្ធិក្នុងការ បដិសេធការសម្ភាសន៍ និងសិទ្ធិនៅស្ងៀមស្ងាត់!

ប្រសិនជា មានមូលហេតុណាមួយ ដែល ICE (អាយស៊ីអុិ) ព្យាយាមធ្វើបទសំភាសន៍រូបអ្នកមែន អ្នកអាចប្រើប្រាស់ សិទ្ធិស្ងាត់ស្បៀមរបស់អ្នក។ អ្នកអាចស្នើសុំ ឱ្យមានវត្តមានមេធាវីរបស់អ្នក នៅទីនោះផងដែរ។ ប្រសិនជារូបអ្នក មិនមានមេធាវីអន្តោ ប្រវេសន៍នេះទេ អ្នកអាចស្វែងរក-មួយ តាមការចំណាយផ្ទាល់ខ្លួនរបស់អ្នក ឬទីកន្លែងខ្លះៗ តាមអង្គការស្ថាប័នមិនរកប្រាក់ចំណេញក្នុងតំបន់។

## អ្នកមានសិទ្ធិក្នុងការដឹងថា ភ្នាក់ងារ ICE (អាយស៊ីអ៊ី) កំពុងស្វែងរកមើលអ្នក នៅក្នុងពន្ធនាគារ។

នៅក្រោមច្បាប់ ទង្វើការពិត  TRUTH Act (ទ្រូអាក់)នេះ ប៉ូលិស និងនគបាល ត្រូវតែផ្តល់ឱ្យដល់រូបអ្នក នូវច្បាប់ ចម្លងឯកសារ ,

ដែលខាង ICE (អាយស៊ុអុិ) បានទុក (សំណើររបស ICE ទៅពន្ធនាគារ ដើម្បីទុករូបអ្នក ក្នុងពេលវេលាបន្ថែមទៀត) ឬស្នើសុំការជូនដំណឹង (សំណើររបស់ ICE ទៅពន្ធនាគារ នៃកាលបរិឆ្ឆេត និងពេលវេលា ដែលអ្នក នឹងត្រូវបានដោះលែងចេញពីពន្ធនាគារ)។

ប៉ូលិស និងនគបាល ត្រូវតែប្រាប់ដល់រូបអ្នក និងមេធាវីរបស់អ្នក ឬមនុស្សណាម្នាក់ដែលអ្នកបានជ្រើសរើស - ក្នុងការសរសេរ ប្រសិនបើ ពួកគេនឹងប្រាប់ទៅ ICE (អាយស៊ីអុិ)នៅពេលណាដែលអ្នក ត្រូវបានដោះលែងពីពន្ធនាគារ។  នេះនឹងផ្តល់ឱ្យអ្នកនូវពេលវេលាបន្ថែមទៀត ដើម្បីត្រៀមខ្លួន ប្រឆាំងនឹងករណីយរបស់អ្នក។

ក្នុងករណីភាគច្រើន គឺជាការប្រឆាំងនឹងច្បាប់ពន្ធនាគារក្នុងស្រុក ក្នុងការឃុំខ្លួននរណាម្នាក់ ដើម្បីពន្យាពេលវេលា បន្ថែមទៀត គ្រាន់តែសម្រាប់គោលបំណងនិរទេសនេះ។ ប្រសិនជា ស្នងការភ្នាក់ងារច្បាប់ព្រហ្មទ័ណ្ឌក្នុងស្រុក - ដូចជា ប៉ូលិស ឬនគបាល -  ដែលបានឃុំខ្លួនអ្នកទុក លើករណី ICE (អាយស៊ីអុិ) ដោយគ្មានមូលហេតុចេញបញ្ជាពីចៅក្រម ឱ្យពួកគេអាចប្រើប្រាស់បាន  ហើយពួកគេ អាចនឹងមានការបង់សំណងទៅឱ្យរូបអ្នក។